កុមាររៀន
កុមារចេះ
ក ១ ២៣

# ខ្ទីងចង់មានមិត្ត



## កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូង នៃក្រសួងអប់រំ យុវជន និងកីឡា


រឿង ៖ **ខ្ទីងចង់មានមិត្ត**

និពន្ធដោយ ៖ **លោក ចាន់ សុខអៀង**

កែសម្រួលដោយ ៖ **អ្នកស្រី ហ៊ុយ ឆេងរតនា**

វិចិត្ររូបភាពដោយ ៖ **លោក អែល ហ៊ុយណូ**



សៀវភៅនេះត្រូវបានបោះពុម្ពផ្សាយក្រោមអាជ្ញាប័ណ្ណ CC BY-SA ។



សៀវភៅនេះត្រូវបានបង្កើតឡើងសម្រាប់កម្មវិធីកុមាររៀនកុមារចេះ ដែលជាកម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីជំនួយពីពលរដ្ឋអាមេរិក។


ដើម្បីស្វែងរកសៀវភៅនេះនិងសៀវភៅដទៃទៀតសម្រាប់កុមារ លោកអ្នកអាចចូលទៅកាន់ទំព័រហ្វេសប៊ុកកុមាររៀនកុមារចេះ

www.facebook.com/123komar




ឬគេហទំព័រ តោះអាន ឬទាញយកកម្មវិធីបណ្ណាល័យឌីជីថលតោះអាន

Let's Read
www.LetsReadAsia.org

ខ្ទីងជាកូនទោលក្នុងគ្រួសារ។ ខ្ទីងក្រៀមក្រំ ដោយសារគ្មានមិត្តលេងជាមួយ។



រីឯក្ងាន ក្ដាន់និងក្រសារជាមិត្តនឹងគ្នា។ ពួកគេលេងសើចជាមួយគ្នា ដោយមិនខ្វល់ខ្វាយឡើយ។



នៅពេលមួយ ខ្ទីងខំខ្នះខ្នែងដើររកមិត្ត។
ខ្ទីងក៏បានជួបក្ងាន។ ក្ងានដក កក្ងិចក្ងក់
កំពុងដើរនៅក្រោម
ដើមក្ងោក។



ខ្ទីងសួរក្ងាន ៖ «តើយើងអាចក្លាយជាមិត្តនឹងគ្នាបានដែរទេ?»។ ក្ងានតប ៖ «ខ្លួនបងខ្លាំងតែបងមិនអាចក្រាបពងដូចខ្ញុំឡើយ។ ដូចនេះយើងមិនអាចក្លាយជាមិត្តនឹងគ្នាទេ»។



ខ្ទីងដើរទៅមុខទៀត ក៏បានជួបក្ដាន់។
ក្ដាន់កំពុងផឹកទឹកនៅក្បែរទួលខ្ពស់មួយ។



ខ្ទីងសួរក្តាន់ ៖ «តើយើងអាចក្លាយជាមិត្តនឹងគ្នាបានដែរទេ?»។ ក្តាន់តប ៖ «ខ្លួនបងខ្លាំង តែបងមិនអាចលោតបានខ្ពស់ដូចខ្ញុំឡើយ។ ដូចនេះ យើងមិនអាចក្លាយជាមិត្តនឹងគ្នាទេ»។



ខ្ទីងដើរទៅមុខទៀត ក៏បានជួបក្រសារ។
ក្រសារមានឫកក្រអឺតក្រទមកំពុងឈរ
នៅក្រោមដើមក្រសាំង។



ខ្ទីងសួរក្រសារ ៖ «តើយើងអាចក្លាយជាមិត្តនឹងគ្នាបានដែរទេ?»។ ក្រសារតប ៖ «ខ្លួនបងខ្លាំង តែបងមិនចេះហើរដូចខ្ញុំឡើយ។ ដូចនេះ យើងមិនអាចក្លាយជាមិត្តនឹងគ្នាទេ»។



ខ្ទីងក្រៀមក្រំ ដោយរកមិត្តមិនបាន។
ខ្ទីងខ្វល់ខ្វាយក្នុងចិត្តពេកក្រៃ។



រំពេចនោះ ខ្ទីងឮសំឡេងខ្សៀវខ្សារ។ ខ្លាមួយ ក្បាលកំពុងដេញចាប់ក្ងាន ក្តាន់និងក្រសារ។



ក្ងាន ក្ដាន់និងក្រសារភ័យខ្លាចគ្រប់គ្នា។
ក្ងាននិងក្ដាន់នាំគ្នារត់គ្មានងាកក្រោយឡើយ។





រីឯក្រសារខ្វល់ខ្វាយខ្លាចខ្លាស៊ីមិត្ត
របស់គេ។ ខ្ទីងឃើញពួកគេរត់ទាំង
ភ័យខ្លាច ក៏មានចិត្តអាណិតអាសូរ។

ខ្ទីងសួរក្រសារអំពីដំណើររឿង។ ក្រសារយំខ្សឹកខ្សួលរៀបរាប់៖ «ខ្លាកំពុងដេញចាប់ស៊ីមិត្តរបស់ខ្ញុំហើយ»។



ខ្ទីងខំខ្នះខ្នែងជួយពួកគេគ្រប់ៗគ្នា។
ខ្ទីងក្លាហានទៅសុំចចារជាមួយខ្លា។
ខ្ទីងនិយាយ៖«សូមបងខ្លាកុំស៊ីមិត្តរបស់ខ្ញុំ»។



ខ្លាក្អេងក្អាងមិនខ្វល់ខ្វាយនឹងខ្ទីងឡើយ។

«ឯងចេញទៅ! កុំចេះខ្វល់ខ្វាយរឿងគេ» ។

ខ្ទីងនិយាយ ៖ «ឯងកុំក្អេងក្អាងពេក»។



ខ្ទីងខឹងក្តៅក្រហាយ ក៏បបួលគ្នាដេញផល់ខ្លាវិញ។ ក្ងាន ក្តាន់និងក្រសារក៏ដេញខ្លាជាមួយខ្ទីងដែរ។



ខ្លាភ័យខ្លបខ្លាចក៏រត់គេចខ្លួនបាត់ទៅ។ ក្ងាន ក្ដាន់និងក្រសារ អរគុណខ្ទីងដែលបានជួយ ពួកគេ។ ពួកគេក៏ពិគ្រោះគ្នាយកខ្ទីងជាមិត្តដែរ។



ក្ងាននិយាយ ៖ «ខ្ទីងមិនចេះដូចពួកយើង តែ ខ្ទីងក្លាហានជួយពួកយើង»។

ខ្ទីងរីករាយណាស់ដែលមានមិត្តនឹងគេ។

ពួកគេនាំគ្នាសើចក្អាកក្អាយទទួលគ្នាជាមិត្ត។



# ពន្យល់ពាក្យ

| | | |
|---|---|---|
| ១. **កូនទោល** | : | កូនតែមួយនៅក្នុងគ្រួសារ |
| ២. **ក្រៀមក្រំ** | : | មិនសប្បាយចិត្ត |
| ៣. **ខ្វល់ខ្វាយ** | : | ព្រួយចិត្ត |
| ៤. **ខ្នះខ្នែង** | : | ខំប្រឹង ខិតខំ |
| ៥. **ក្រអឺតក្រទម** | : | ដែលសម្ដែងឫកពាបែបឆ្មើងឆ្មៃ |



## សំណួរ

១. មុនដំបូង ហេតុអ្វីបានជាខ្ទីងនៅតែម្នាក់ឯង?

២. មុនដំបូង ហេតុអ្វីបានជាក្ងាន ក្ដាន់និងក្រសារ មិនព្រមធ្វើជាមិត្តនឹងខ្ទីង?

៣. នៅចុងបញ្ចប់រឿង តើខ្ទីងបានក្លាយជាមិត្តរបស់ក្ងាន ក្ដាន់និងក្រសារដែរឬទេ? ហេតុអ្វី?

៤. ចុះកូនវិញ បើនរណាម្នាក់សុំកូនធ្វើជាមិត្ត តើកូនយល់ព្រមដែរឬទេ? ហេតុអ្វី?







IPEA, Kg.Chhnang, 789 copies, SSK, Oct. 2022

បន្ទាប់ពីរៀនចប់មេរៀនទី៩ វំពុក **«ព្យញ្ជនៈផ្ញើជើង ឆ្ដ ឆ្គ ឆ្ព»** នៃសៀវភៅថ្នាក់ទី២ សិស្សនឹងអាចអានសៀវភៅរឿងនេះបានដោយខ្លួនឯង ដោយពុំចាំបាច់មានអ្នកដទៃជួយឡើយ។

ទោះជាយ៉ាងណា សិស្សថ្នាក់ទី១ ក៏អាចអានសៀវភៅរឿងនេះជាមួយគ្រូបានដែរ ដោយពួកគេអាចមើលនិងរៀបរាប់អំពីរូបភាពនៅក្នុងសៀវភៅរឿងនេះ ហើយអានពាក្យនិងតួអក្សរដែលពួកគេស្គាល់។

សូមចងចាំថា នៅពេលសិស្សចាប់ផ្ដើមអានសៀវភៅកាន់តែឆាប់ គឺកាន់តែប្រសើរសម្រាប់ពួកគេ!



កុមាររៀន កុមារចេះ

កម្មវិធីជាតិស្ដីពីការសិក្សាកម្រិតថ្នាក់ដំបូង
នៃក្រសួងអប់រំ យុវជន និងកីឡា

9 789924 560364 >
បោះពុម្ពឆ្នាំ២០២២